ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥ និងទិសដៅការងារខែមករា ឆ្នាំ២០២៦

នៅក្នុងខែធ្នូ ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម រួមមាន៖**

  ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី៖

  ១- ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

  ២- ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

  ៣- ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។

  ៤- ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីនស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។

  ៥- ការអនុម័តយល់ព្រមលើពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីស្តីពី

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបគេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និង

៦- កំណត់កាលបរិច្ឆេទ របៀបវារៈ បន្តសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥។

❖ បើកសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ចំនួន៥ច្បាប់ខាងលើ។

❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ចំនួន៥ច្បាប់។

❖ បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផ្ទៃក្នុងអំពីការស្រាវជ្រាវរបស់អគ្គនាយកដ្ឋានស្រាវជ្រាវលើសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងសេចក្ដីព្រាងច្បាប់ស្ដីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង

❖ បានអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាមួយគណៈកម្មការទី៤ និងទី៦រដ្ឋសភា នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិទី៤ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី៤ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធាន (ក.ជ.ប.ព) នៅអង្គភាពប្រឆាំងអំពើពុករលួយ។

## ២-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញថ្វាយ និងទទួលព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្ដេចយាងចូលរួមកម្មវិធីបណ្ឌិត្យសភាវិទ្យាសាស្ត្រ នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិតេជោ និង
  - បានអញ្ជើញតាមដានដោយយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះសភាពការណ៍វិវាទព្រំដែនកម្ពុជា-ថៃ និងផ្ដល់យោបល់យុទ្ធសាស្ត្រយោធាដល់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និងបណ្ដាមេទ័ព។

❖ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា៖

- ***សកម្មភាពដឹកនាំកិច្ចប្រជុំ៖***
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និង ទីប្រឹក្សា ថ្នាក់ដឹកនាំ សមាជិកខុទ្ទកាល័យ និងក្រុមការងារ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈ៖

    ១- សភាពការណ៍នៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ។

    ២- ពិនិត្យរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ២០២៥។

    ៣- ពិនិត្យរបាយការណ៍ចំណូល-ចំណាយប្រចាំឆ្នាំ២០២៥។

    ៤- ពិនិត្យផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦ និង

    ៥- បញ្ហាផ្សេងៗ។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រុមទីប្រឹក្សា ក្រុមជំនួយការខុទ្ទកាល័យ និងមន្ត្រីពិធីការ ដើម្បីត្រៀមរៀបចំចុះសួរសុខទុក្ខវីរកងទ័ពរងរបួស ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ និងមន្ទីរពេទ្យកាល់ម៉ែត នៅវិមានព្រឹទ្ធសភា។
- **បេសកកម្មក្នុងប្រទេស៖**
  - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ជូនវីរយុទ្ធជន និងគ្រួសារយុទ្ធជន ចំនួន៣០០គ្រួសារ ក្នុងបរិវេណទីស្នាក់ការកងពលតូចថ្មើរជើងលេខ៤២ និងសម្ភារសិក្សាជូនដល់សិស្សានុសិស្សនៃសាលាបឋមសិក្សាតាមន្តសែនជ័យ នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។
  - បានអញ្ជើញប្រគល់ផ្ទះ ចំនួន២ខ្នង និងសម្ភារប្រើប្រាស់ចាំបាច់ក្នុងផ្ទះជូនដល់ប្រជាពលរដ្ឋ ចំនួន២គ្រួសារ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារប្រើប្រាស់ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសប្បុរសជននានា ចែកជូនដល់ប្រជាពលរដ្ឋក្រីក្រ ចំនួន៦០គ្រួសារ នៅស្រុកកងមាស និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
  - បានចាត់ទីប្រឹក្សាអញ្ជើញចុះសាកសួរសុខទុក្ខ និងនាំយកអំណោយរបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងសប្បុរសជន និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ ជូនវីរយុទ្ធជន ក្នុងបរិវេណទីស្នាក់ការកងពលតូចថ្មើរជើងលេខ៤២ និងកងអនុសេនាធំទី១ នៅស្រុកសំរោង ខេត្តឧត្តរមានជ័យ។
  - បានចាត់ក្រុមការងារមន្ត្រីខុទ្ទកាល័យអញ្ជើញចុះសាកសួរសុខទុក្ខ និងនាំយកអំណោយរបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងសប្បុរសជន ព្រមទាំងសប្បុរសជនខ្មែរនៅប្រទេសជប៉ុន និងសម្ភារមួយចំនួនទៀត ជូនវីរយុទ្ធជនការពារដែនអធិបតេយ្យជាតិ និងបូរណភាពទឹកដី នៅខេត្តឧត្តរមានជ័យ និង
  - បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព **លោកវរសេនីយ៍ត្រី ហេង ចាន់ធឿន** មេបញ្ជាការកងអនុសេនាតូចលេខ២ និង**លោកអនុសេនីយ៍ទោ អ៊ាន សុខ** មេក្រុម

លេខ២ កងអនុសេនាតូចលេខ២ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និង**វរសេនីយ៍ត្រី ហែន ភីណា** នៅកងពលតូចលេខ៩ ក្នុងវរសេនាតូចកងពលលេខ៣៩៤។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
    - បានអញ្ជើញថ្វាយ និងទទួលព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងចូលរួមកម្មវិធីបណ្ឌិត្យសភាវិទ្យាសាស្ត្រ នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។
    - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អមដំណើរដោយ **ឯកឧត្តម គី តិច** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ព្រមទាំងសមាជិកព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខវីរយុទ្ធជនដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ និងមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ និង
    - បានអញ្ជើញចូលរួមក្នុងពិធីជប់លៀង ក្នុងឱកាសអបអរសាទរឆ្នាំថ្មី ឆ្នាំសកល២០២៦ នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតរុស្ស៊ី។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ៉ានា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រុមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីពិភាក្សាអំពីការរៀបចំផែនការបេសកកម្មរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមបណ្តាក្រសួង ស្ថាប័ន និងរាជធានី ខេត្ត នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- **សកម្មភាពចុះមូលដ្ឋាន៖** បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកតាសេក ដើម្បីស្តាប់បញ្ហាប្រឈម សំណូមពរ និងពិនិត្យវឌ្ឍនភាពការងាររបស់សង្កាត់ នៅសាលាសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
    - បានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបឆ្នាំទី៣៤ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា (៧ ធ្នូ ១៩៩១- ៧ ធ្នូ ២០២៥) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា (វត្តស្វាយពពែ) ខណ្ឌចំការមន រាជធានីភ្នំពេញ។
    - បានអញ្ជើញធ្វើបទបាឋកថាស្តីពី "គោលនយោបាយ និងឱកាស" ក្នុងវិស័យស្វាយចន្ទី ដល់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។
    - បានអញ្ជើញចុះសួរសុខទុក្ខវីរកងទ័ពដែលកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យព្រះកេតុមាលា រាជធានីភ្នំពេញ។

- បានអញ្ជើញចុះសួរសុខទុក្ខយោធិនរបួសដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ធំ និងចែកអំណោយរួមមាន អង្ករ ទឹកដោះចន្ទី អាវយឺត និងថវិកាមួយចំនួន។
- បានអញ្ជើញថ្វាយបង្គំព្រះសង្ឃគង់នៅវត្តសំពៅមាសកែវនិមិត្ត ព្រមទាំងប្រគេនទេយ្យទានរួមមាន អង្ករ១តោន តង់ចំនួន១៥ និងបច្ច័យសម្រាប់កសាងវត្ត នៅស្រុករវៀង ខេត្តព្រះវិហារ។
- បានអញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយរួមមាន អង្ករ ទឹកដោះចន្ទី សាច់ជ្រូក ពងមាន់ស្ងោរ ឆៃប៉ូវផ្អែម ទឹកសុទ្ធ មីជាតិ តង់ ថ្នាំពេទ្យ ប្រេងខ្យល់ សម្លៀកបំពាក់ និងថវិកាមួយចំនួន ដល់បងប្អូនភៀសសឹក នៅខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ និង
- បានអញ្ជើញដឹកនាំគណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ គោរពវិញ្ញាណក្ខន្ធសព **ឧបាសិកា សេង យុអៀន** ត្រូវជាម្ដាយបង្កើតរបស់ **លោក លឹម សុភា** អភិបាលនៃគណៈអភិបាលខណ្ឌជ្រោយចង្វារ នៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ផ្ដល់ជូនវីរយុទ្ធជនដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា។
- បានអញ្ជើញរៀបចំសម្ភារ និងអំណោយមនុស្សធម៌សម្រាប់ផ្ដល់ជូនជនភៀសសឹក និងវីរកងទ័ពកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅរាជធានីភ្នំពេញ។
- បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ចាំបាច់ ថវិកាផ្ដល់ជូនគ្រួសារកងទ័ពជួរមុខ និងនាយទាហាន នាយទាហានរង និងពលទាហាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅកងពលតូចអន្តរាគមន៍លេខ៩ កងពលធំអន្តរាគមន៍លេខ៣ ទិសទី១ (មុំបី) ប្រាសាទព្រះវិហារ នៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ និងនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- បានអញ្ជើញចូលរួមពិធីជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ និងថវិកាជូនវីរយុទ្ធជនការពារប្រាសាទតាមាន់ធំ ប្រាសាទតាក្របី និងក្រុមគ្រួសារយុទ្ធជន និងសម្ភារសិក្សាជូនដល់សិស្សានុសិស្សនៃសាលាបឋមសិក្សាតាមាន់សែនជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅខេត្តឧត្តរមានជ័យ។
- បានអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារ និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចក្រឡាហោម ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅស្រុកកញ្ជៀច ខេត្តព្រៃវែង។

- បានអញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់អគារ និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅស្រុកស្វាយទាប ខេត្តស្វាយរៀង។
- បានអញ្ជើញចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងឆ្លងសមិទ្ធផលនានា ក្នុងវត្តកំចាយមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**លោកជំទាវ កែ សួនសុភី សសុខា** នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមពិធីប្រគល់អំណោយមនុស្សធម៌របស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ជូនរដ្ឋបាលខេត្តតាកែវ និងរដ្ឋបាលខេត្តកំពត។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ(ខេត្តព្រៃវែង)-តឹនណាម(ខេត្តតៃនិញ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម ផាម មិញជីញ នាយករដ្ឋមន្ត្រី**នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីចែកអំណោយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយខ្យល់កន្ត្រាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ។
- បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី នៅទីស្តីការក្រសួងបរិស្ថាន។
- បានអញ្ជើញចូលរួមជាគណៈអធិបតី និងជាកិត្តិយសក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុន ម៉ានី** អនុប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្ររាជធានីភ្នំពេញ។
- បានអញ្ជើញចុះទស្សនកិច្ច និងជួបសំណេះសំណាលជាមួយសិប្បករតម្បាញហូល ផាមួង ក្រមា សារុងសូត្រ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ និងគណៈកម្មការសហគមន៍នេសាទត្រពាំងរពៅ ស្រុកទឹកឈូ ខេត្តកំពត។
- បានអញ្ជើញនាំយកអំណោយមនុស្សធម៌របស់ព្រឹទ្ធសភា ប្រគល់ជូនរដ្ឋបាលខេត្តតាកែវ នៅមន្ទីរសុខាភិបាលខេត្តតាកែវ។

- បានអញ្ជើញនាំយកអំណោយមនុស្សធម៌របស់ព្រឹទ្ធសភា ប្រគល់ជូនរដ្ឋបាលខេត្តកំពត នៅមន្ទីរសុខាភិបាលខេត្តកំពត។
- បានអញ្ជើញចូលរួមជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា(AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខេត្តកណ្តាល ខេត្តត្បូងឃ្មុំ និងខេត្តស្វាយរៀង និង
- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១១៥លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១១២លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ប្រចាំការក្នុងស្ថានការណ៍នៃការប្រយុទ្ធប្រឆាំងទប់ទល់នឹងការឈ្លានពានប្រដាប់អាវុធរបស់យោធាថៃមកលើដែនអធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារផ្សេងៗ សម្លៀកបំពាក់កូនក្មេង និងថវិកា សម្រាប់ប្រគល់ជូនកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក នៅវិមាន៧មករា និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន៤លើក។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នាំយកអំណោយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដូចជា គ្រឿងឧបភោគ បរិភោគ ឱសថ និងសម្ភារប្រើប្រាស់ផ្សេងៗ ប្រគល់ជូនដល់វីរកងទ័ពការពារប្រាសាទតាមាន់ ប្រាសាទតាក្របី និងប្រាសាទខ្នារ នៅសាលាស្រុកក្រឡាញ់ ខេត្តឧត្តរមានជ័យ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជូនពរ **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងឱកាសឆ្នាំសកល២០២៦ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាៈ
  - អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **សេង យុអៀន** ម្តាយបង្កើត **លោក លឹម សុភា** អភិបាលនៃគណៈអភិបាលខណ្ឌជ្រោយចង្វារ នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និង
  - អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោកស្រី សម បុប្ផា** ប្រធានការិយាល័យជំនួយការគណៈកម្មការទី៥នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមជួបតំណាងធនាគារអេស៊ីលីដា ដែលបាននាំយកថវិកាវិភាគទានរបស់ធនាគារអេស៊ីលីដា ចំនួន ២០០លានរៀល ជូនដល់មូលនិធិព្រឹទ្ធសភាសម្រាប់គាំទ្រកងទ័ពជួរមុខ និងជនភៀសសឹក (ព.ស.ក.ទ និង ជ.ភ.ស) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម សាស្ត្រាចារ្យ ហេង តៃគ្រី** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅគេហដ្ឋាននៃសព សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា **ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីប្រកាសចូលកាន់តំណែង **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាៈ
  - បានអញ្ជើញអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នាំយកអំណោយ និងថវិការបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជូនវីរយុទ្ធជនរបួសក្នុងការប៉ះទង្គិចគ្នារវាងកងទ័ពកម្ពុជា-ថៃ ដែលកំពុងសម្រាកព្យាបាលតាមមន្ទីរពេទ្យនានា ក្នុងរាជធានីភ្នំពេញ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ, មន្ទីរពេទ្យព្រះអង្គឌួង, មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះកេតុមាលា។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារក្រោមអធិបតីភាព **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅបន្ទប់ប្រជុំអនុប្រធានទី១ព្រឹទ្ធសភា។
  - បានអញ្ជើញចូលរួមកម្មវិធីជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកតាសេក ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា

នៅសង្កាត់ព្រែកតាសេក និង

- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤លើក។

❖ **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤លើក។

- បានទទួលពាក្យបណ្តឹង ចំនួន៦បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន១១បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន២បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន១បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន៣បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន១៥បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន១៤បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

**- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា និងវិមាន៧មករា ចំនួន៣លើក រួមមាន៖

- **ឯកឧត្តម** Christian DesRoches ឯកអគ្គរដ្ឋទូតកាណាដា។
- **ឯកឧត្តម** Marketa Kolc Hajkova ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក និង
- **ឯកឧត្តមសាស្ត្រាចារ្យ** Xie Chuntao អនុប្រធានប្រតិបត្តិសាលាបក្សនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន (CCPS) និងជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិនអាណត្តិទី២០។

❖ ឯកឧត្តម **អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំការងារដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង(APF) ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន២លើក រួមមាន៖
  - បានអនុញ្ញាតឱ្យ **ឯកឧត្តម គី តិច** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ចូលជួបសម្តែងការគួរសម នៅបន្ទប់ប្រជុំឧទ្ទកាល័យឯកឧត្តមអនុប្រធានទី១ វិមានព្រឹទ្ធសភា។
  - បានទទួលជួប និងទទួលអំណោយរបស់គណៈប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន (ACSC) ជូនវីរយុទ្ធជនសមរភូមិមុខតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងជនភៀសសឹក នៅបន្ទប់ឧទ្ទកាល័យឯកឧត្តមអនុប្រធានទី១ វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ៉ា** អនុប្រធានទី២ព្រឹទ្ធសភា៖

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមជាកិត្តិយសអបអរសាទរ **ឯកឧត្តមបណ្ឌិត ចែម វីឡាំ** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស Grand Cross of Merit with Star of the Order of Merit of the Federal Republic of Germany របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ពី**ឯកឧត្តម Frank Walter Steinmeier** ប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅនិវេសនដ្ឋាន **ឯកឧត្តម Stefan Messerer** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
  - បានអញ្ជើញចូលរួមកម្មវិធីជប់លៀងជំណាច់ឆ្នាំ២០២៥ របស់សមាគមអតីតនិស្សិតខ្មែរមកពីជប៉ុន (JAC) ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម UENO Atsushi** ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអតីតនិស្សិតបញ្ចប់ការសិក្សាមកពីជប៉ុន នៅសណ្ឋាគារ Raffles Le Royal Phnom Penh។

❖ **ឯកឧត្តម ងី ច័ន្រ្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី កិច្ចការនយោបាយនៃសភាតំបន់អាស៊ី (APA) នៅទីក្រុងម៉ាសាដ សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់។

❖ **ឯកឧត្តម យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និង**ឯកឧត្តម ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអនុគណៈកម្មការនៃបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង(APF) តាមប្រព័ន្ធនិម្មិត ផ្សាយចេញពីទីក្រុងប៉ារីស សាធារណរដ្ឋបារាំង។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និង**ឯកឧត្តមបណ្ឌិត ឡូយ សុផាត** ប្រធានគណៈកម្មការទី៣រដ្ឋសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រុមហ៊ុនជប៉ុន FOREX SENDAI តាមប្រព័ន្ធនិម្មិត ក្នុងគោលបំណងសិក្សាលទ្ធភាពវិនិយោគបង្កើតរោងចក្រផលិតដីកំប៉ុស ជីសរីរាង្គប្រកបដោយគុណភាពខ្ពស់ និងតម្លៃសមរម្យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រុមហ៊ុនជប៉ុន FUJIURA LTD ក្នុងគោលបំណងសិក្សាអំពីឱកាសវិនិយោគលើការអភិវឌ្ឍដំណាំកសិកម្ម និងកសិឧស្សាហកម្ម។

❖ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្របំពេញទស្សនកិច្ច នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡាំ** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖

- បានអញ្ជើញប្រជុំត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

- បានអញ្ជើញជប់លៀងជាមិត្តភាពជូន **ឯកឧត្តម Stefan Messerer** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅភោជនីយដ្ឋាន TOPAZ និង
- បានអញ្ជើញចូលជួបសម្តែងការគួរសមជាមួយ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា និងទទួលអនុសាសន៍មុនចាកចេញទៅបំពេញតួនាទីជាអគ្គលេខាធិការ អន្តរសភាអាស៊ានអាយប៉ា (AIPA) សម្រាប់អាណត្តិទី៧ នៅវិមានរដ្ឋសភា។

❖ **ឯកឧត្តម អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត ដើម្បីចែករំលែកព័ត៌មានបឋមសម្រាប់កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិសភាប្រើភាសាបារាំង (APF) នៅវិមានព្រឹទ្ធសភា និង
- បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការផ្លាស់ប្តូរការអនុវត្តដាក់ស្តែងលើប្រធានបទស្តីពីសញ្ញាណនៃផលប្រយោជន៍ផ្ទាល់ខ្លួន តាមប្រព័ន្ធនិម្មិត នៅវិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិចលនាសេរីនិយមអន្តរជាតិ (Liberal International) លើកទី២០៩ នៅទីក្រុង Hague ប្រទេសហូឡង់។

❖ សមាជិក សមាជិកាព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមសភាជាតិប្រើភាសាបារាំង (APF) ស្តីពី ការត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង ឆ្នាំ២០២៦ នៅព្រះរាជាណាចក្រកម្ពុជា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
- បានអញ្ជើញចូលរួមកម្មវិធីអបអរសាទរ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស Grand Cross of Merit with Star of the Order of Merit of the Federal Republic of Germany របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ពី **ឯកឧត្តមបណ្ឌិត Frank Walter Steinmeier** ប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅនិវេសនដ្ឋានឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ រាជធានីភ្នំពេញ។

**- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ប្រមុខរដ្ឋស្តីទី** ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវអន្តរជាតិ ចំនួន៣លើក នៅវិមានព្រឹទ្ធសភា និង វិមាន៧មករា។
- បានអញ្ជើញចូលរួមពិធីជប់លៀងបុណ្យណូអែល (Christmas Reception with Carols) នៅនិវេសនដ្ឋានឯកអគ្គរាជទូតនៃចក្រភពអង់គ្លេសប្រចាំកម្ពុជា។
- បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូរដ្ឋសភានៃសាធារណរដ្ឋបារាំង ដឹកនាំដោយ **លោក Febrice Robert** អតីតនាយកទទួលបន្ទុកនីតិកម្ម និងត្រួតពិនិត្យព្រឹទ្ធសភាបារាំង ក្នុងឱកាសដែលលោក និងសហការីចូលរួមជាវាគ្មិនគន្លឹះក្នុងសិក្ខាសាលា

បណ្តុះបណ្តាលស្តីពី "កិច្ចការសភា" ក្រោមកិច្ចសហប្រតិបត្តិការរៀបចំដោយសមាគមសភានិយាយភាសាបារាំង (APF) និងមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ដែលប្រព្រឹត្តទៅនៅរដ្ឋសភាកម្ពុជា និងវិមានព្រឹទ្ធសភា។

- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមសភាជាតិកម្ពុជានៃសភាប្រើភាសាបារាំង (APF) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំងឆ្នាំ២០២៦ នៅព្រះរាជាណាចក្រកម្ពុជា និង
- បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបិទសិក្ខាសាលាស្តីពី កិច្ចការសភាសហការរៀបចំដោយរដ្ឋសភា និងព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង ក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសមាគមសភានិយាយភាសាបារាំង (APF) និងមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) នៅវិមានរដ្ឋសភា។

- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ស្ថានទូតឥណ្ឌា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ (CFRD) បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) បណ្ណសារដ្ឋានជាតិ-អន្តរជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ០២៥ និងកំណត់ទិសដៅការងារខែមករា ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដឹកនាំដោយ **ឯកឧត្តម ឈិន កេតនា** ឧបនាយករដ្ឋមន្ត្រី អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ព្រមទាំងមានការចូលរួមពីតំណាងក្រសួងព្រះបរមរាជវាំង ដើម្បីពិនិត្យពិភាក្សាត្រៀមរៀបចំពិធីក្រុងពាលី និងពិធីចម្រើនព្រះបរិត្ត ជាពិសេសត្រៀមលក្ខណៈរៀបចំព្រះរាជពិធីសម្ពោធអគារព្រឹទ្ធសភាថ្មី "វិមានសាមគ្គីភាព" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នាពេលខាងមុខ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមការងារបច្ចេកទេសសាងសង់អគារ បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធាន

គណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ចំនួន២លើក និង

- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ២០២៥ និងទិសដៅបន្ត របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសក្រោម។

## ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានស្នើសុំបុរេប្រទានថវិកា៖
    - សម្រាប់ការទិញម៉ាស៊ីន X-Ray ថ្មី ម៉ាក Rapisscan 920DX ចំនួន០៣គ្រឿង, ខ្លោងទ្វារសុវត្ថិភាព Walkthrough Metal Detector (Metor900M-30M)ចំនួន០៣គ្រឿង, Handheld Metal Detector(28M)ចំនួន០៦គ្រឿង និងUPS(ART6KLI)ចំនួន០៣គ្រឿង និង
    - សម្រាប់ការចំណាយលើបេសកកម្មនៅក្រៅប្រទេសជូន **សម្តេចពិជ័យសេនា ទៀ បាញ់** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញទៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- បានបង្វែរប្រាក់បង់វិភាគទានហានិភ័យការងារ និងភាគទានថែទាំសុខភាព ជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែធ្នូ ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែធ្នូ ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៩៤សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១១៨សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន២៣សំណើ។
- បានថតចម្លងឯកសារ ចំនួន៣,០៣៣ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន៧៤,១១៤សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៧៦លើក ស្មើនឹង២០១នាក់។

- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៩លើក។
- បានទទួលលិខិតចូល ចំនួន៥០៨ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៤៥៨ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៩ច្បាប់ ស្មើនឹង៧២នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៧ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលំហែមាតុភាព នៅរាជធានីភ្នំពេញ ចំនួន៣នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១២លើក។
  - បានជួសផ្កាកេសរកូល នៅខាងមុខខុទ្ទកាល័យថ្នាក់ដឹកនាំ។
  - បានកាប់ដើមក្រញូង ដើមស្លា ដើមសាគូរ៉ា និងដើមត្នោត ក្នុងបរិវេណព្រឹទ្ធសភា។
  - បានដាំដើមជ្រៃលាប ដើមហ្វ្រង់ និងដើមឫស្សី។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ប្រចាំខែធ្នូ ឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖
  - មន្ត្រីរាជការក្របខណ្ឌ ចំនួន៧២១នាក់ (ស្រី២៩២) ក្នុងនោះមន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់, មន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម ចំនួន៥នាក់, មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៦នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩២នាក់ (ស្រី៣៦នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន១ច្បាប់ និងលិខិតបង្គាប់ការ ចំនួន៧ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៦ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែធ្នូ ឆ្នាំ២០២៥។
- បានបើកវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន១វគ្គ ស្តីពី ការរៀបចំតាក់តែងលិខិតរដ្ឋបាល និងកិច្ចការលេខាធិការសភា មានសិក្ខាកាមចូលរួម ចំនួន៤៣នាក់។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៦នាក់ ចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន២វគ្គ រួមមាន៖
  - វគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញរដ្ឋបាលសាធារណៈ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា និង

- វគ្គបណ្តុះបណ្តាលខ្លីស្តីពី របៀបសរសេរអត្ថបទសុីជម្រៅ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលព័ត៌មាន Fresh News។

- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានរៀបចំបន្ទប់ និងបំពាក់សម្ភារការិយាល័យ **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា។
  - បានពង្រីកចំណតរថយន្តក្រោមដើមជ្រៃ និងរៀបចំចំណតថ្មីសម្រាប់រថយន្តអគ្គិសនី នៅក្រោយអគារF និង
  - បានបំពាក់ឆត្រ និងកញ្ចក់សុវត្ថិភាពតាមកែងផ្លូវ ជូនអង្គភាពការពារព្រឹទ្ធសភា និងច្រកចេញ-ចូល P3។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៨៣គ្រឿង/លើក។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានបន្តស្រាវជ្រាវ និងរៀបចំសរសេរចងក្រងសៀវភៅអំពីប្រវត្តិ និងការប្រើប្រាស់អគារមួយចំនួននៅវិមានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួងស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥។

### ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន២៧ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានីតិកាលទី៥ ជូន៖
  - ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៣លើក និង
  - ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៦លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និង

រៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៣៥លើក។

- បានប្រមូលឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលបានពិនិត្យ ចុះបញ្ជី និងប្រថាប់ត្រា អង្គភាពប្រឆាំងអំពើពុករលួយ ជូនសាមីខ្លួន ឬអ្នកតំណាង ចំនួន៣ច្បាប់។
- បានសម្របសម្រួល ចុះបញ្ជី និងបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទទួលការតែងតាំងថ្មី ទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន១នាក់ និង
- បានប្រមូល និងតាមដានព័ត៌មានពាក់ព័ន្ធអំពើពុករលួយជាតិ-អន្តរជាតិ ដើម្បីផ្សព្វផ្សាយផ្ទៃក្នុង និងរក្សាទុកជាជំនួយស្មារតីជូនថ្នាក់ដឹកនាំ ចំនួន៧អត្ថបទ។

**៤.៤-ការងារស្រាវជ្រាវ៖**

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៦ច្បាប់។
- បានធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ជូនគណៈកម្មការទី២ព្រឹទ្ធសភា។
- បានធ្វើបទបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវសេចក្តីព្រាងច្បាប់ស្តីពី "អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា" នៅបន្ទប់ប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានតាមដាន និងចងក្រងឯកសារយុទ្ធសាស្ត្រជាតិស្តីពី ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែធ្នូ ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃចំនួន ២១៤ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៥៣-៥៧ ឆ្នាំ២០២៤)។

**៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៤លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,១២២លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៥១លើក។

- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៣លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន៥លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥។
- បានរៀបចំផលិត និងផ្សព្វផ្សាយៈ
    - ប្រតិទិនការងារឆ្នាំ២០២៦ ចំនួន៤៥០ច្បាប់។
    - ប្រតិទិនប្រចាំឆ្នាំ២០២៦ ចំនួន១,៥០០ច្បាប់ និង
    - សៀវភៅទិនានុលេខន៍ ចំនួន១៥០០ក្បាល។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១៥៩គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៥៦លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន១៥ក្បាល ព្រមទាំងបានដាក់លេខកូដសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី-សងសៀវភៅ ចំនួន៧ក្បាល និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១៤ ចំនួន៦៤៨ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន២៨សំណុំ។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិៈ**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣៥លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាគោរពជូន ឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន៥៦លិខិត។
- បានរៀបចំលិខិតឆ្លើយតប កំណត់ទូត និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៦៧ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំឆ្នាំ២០២៥ ចំនួន១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតជូនសមាជិកព្រឹទ្ធសភា និងលិខិតឆ្លងដែនផ្លូវការជូនទីប្រឹក្សាព្រឹទ្ធសភា និងថ្នាក់ដឹនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៧រូប និង
- បានតាមដានបញ្ហាជម្លោះព្រំដែនគោករវាងកម្ពុជា-ថៃ និងរាយការណ៍ជូនថ្នាក់ដឹកនាំ។

**៤.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្តីពីការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែធ្នូ ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែធ្នូ ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤៤លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែធ្នូ ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-**ទិសដៅការងារខែមករា ឆ្នាំ២០២៦**

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា និង
- ត្រៀមរៀបចំជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីបុណ្យមាឃបូជា នៅបរិវេណឧបដ្ឋានសាលាមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ ខេត្តកណ្តាល។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។

- ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា នៅប្រទេសម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋអាស៊ែបៃហ្សង់។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួម៖
  - កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី ថវិកា និងផែនការនៃសភាតំបន់អាស៊ី (APA) នៅទីក្រុងដូហានៃរដ្ឋកាតា និង
  - មហាសន្និបាតលើកទី១៦ នៃសភាតំបន់អាស៊ី (APA) នៅព្រះរាជាណាចក្របារ៉ែន។
- ត្រៀមទទួលដំណើរ៖
  - ទស្សនកិច្ចរបស់ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន នៅព្រះរាជាណាចក្រកម្ពុជា និង
  - ទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅព្រះរាជាណាចក្រកម្ពុជា។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមរៀបចំពិធីសូត្រមន្ត ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើនអគារថ្មី និងការរៀបចំពិធីសម្ពោធជាផ្លូវការ។
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន៖ ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ
- បន្តផ្តល់សេវាស្រាវជ្រាវ នីតិកម្ម ពិធីការ ព័ត៌មាន និងបដិសណ្ឋារកិច្ច ជាពិសេសការងារការទូតសភា ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែធ្នូនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកខ្លាំងក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារតំណាង ដើម្បីធ្វើសកម្មភាពរួមគ្នាជាមួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងបុព្វហេតុការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី និងបាននាំយកអំណោយជាស្បៀងអាហារ សម្ភារប្រើប្រាស់ជូនកងទ័ពនៅសមរភូមិមុខ និងប្រជាពលរដ្ឋភៀសសឹក

នៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

ក្រៅពីនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្តល់សេវាលើមុខងារនីតិកម្ម ដោយបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បើកសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥ ដោយបានពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជាមួយភ្ញៀវជាតិ និងអន្តរជាតិ បានល្អប្រសើរ។

ថ្ងៃ*ទង្គារ ៧កោច* ខែ*ផល្គុន* ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី *១០* ខែ*មីនា* ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ឡាយ សំកុល**